# អំពីវិទ្យាស្ថានខ្មែរសំរាប់សហប្រតិបត្តិការ និង សន្តិភាព

វិទ្យាស្ថានខ្មែរ សំរាប់សហប្រតិបត្តិការ និងសន្តិភាព (CICP) គឺជាស្ថាប័នវិភាគី ស្ថាបនាគោលនយោបាយឈានមុខមួយ ដែលបាន បង្កើតឡើង ក្នុងឆ្នាំ១៩៩៤ ដើម្បីរួមវិភាគទានក្នុងការលើកកម្ពស់ ការយោគយល់គ្នា ឱ្យកាន់តែប្រសើរឡើង អំពីបញ្ហាជាតិ បញ្ហាតំបន់ និងអន្តរជាតិ ដែលជះឥទ្ធិពលមកលើប្រទេសកម្ពុជា។

ដើម្បីបំពេញបេសកកម្មនេះ វិទ្យាស្ថានខ្មែរសំរាប់សហប្រតិបត្តិការ និងសន្តិភាព បានរៀបចំបង្កើតឱ្យមានបឋកថា សិក្ខាសាលា វេទិកាសាធារណៈ សន្និសីទជាតិ និងអន្តរជាតិ ស្តីអំពីទំនាក់ទំនងអន្តរជាតិ គោលនយោបាយការបរទេស សេដ្ឋកិច្ច និងនយោបាយ។ វិទ្យាស្ថាន ក៏ជាវិទ្យាស្ថានស្រាវជ្រាវ និងបោះពុម្ព ផ្សាយដ៏សកម្មមួយ នៅលើវិស័យសំខាន់ៗ ដើម្បីផ្សព្វផ្សាយ ចំណេះដល់សធារណជន និងជួយផ្តល់យោបល់ ដល់អ្នកធ្វើនយោបាយ លើវិស័យជាច្រើន ដើម្បីរួមចំណែក អភិវឌ្ឍជាតិ តំបន់ និងពិភពលោក។